សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ**

ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្ដល់ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន

១២ កក្កដា ២០១៣

**សូមគោរព លោកស្រី ហាយ៉ាស៊ី អាសាកុ នាយិកាប្រចាំប្រទេសរបស់អង្គការមូលនិធិជប៉ុន - ភី . អេចស៍**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្ដីសោមនស្សរីករាយដើម្បីចុះហត្ថលេខានៅថ្ងៃនេះ លើកិច្ចសន្យាផ្ដល់ជំនួយសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុនជាមួយអង្គការមូលនិធិជប៉ុន- ភី . អេចស៍(PHJ)ដែលនឹងអនុវត្តគម្រោងសហគមន៍ថែទាំសុខភាពមូលដ្ឋានសម្រាប់មាតា និងទារកក្នុងខេត្តកំពង់ធំ(ដំណាក់កាលទី៣)។

នៅពេលដែលការផ្ដល់ជំនួយក្នុងវិស័យសុខាភិបាល ពិសេសការលើកស្ទួយសុខភាពមាតានិងទារកមានសារៈសំខាន់ក្នុងស្មារតីមនុស្សធម៌នោះ ជំនួយនេះក៏ត្រូវបានវាយតំលៃខ្ពស់ក្នុងផ្នែកសេដ្ឋកិច្ចថាជាការវិនិយោគលើកុមារដែលនឹងក្លាយជាអ្នកដឹកនាំសង្គមជាតិនាពេលអនាគតផងដែរ។ យុទ្ធសាស្ត្រចតុកោណដែលជាយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍ជាតិរបស់កម្ពុជាក៏បានបញ្ជាក់យ៉ាងច្បាស់លាស់អំពីកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាដើម្បីលើកស្ទួយស្ថានភាពសុខភាពមាតា និងទារក។ ជាងនេះទៅទៀត ផែនការយុទ្ធសាស្ត្រនៃវិស័យសុខាភិបាលសម្រាប់ឆ្នាំ២០០៨ - ២០១៥ក៏បានផ្ដល់អាទិភាពខ្ពស់ទៅលើការកែលម្អស្ថានភាពសុខភាពមាតា និងទារកផងដែរ។ ទន្ទឹមនឹងនេះ រដ្ឋាភិបាលជប៉ុនក៏បានរួមចំណែកដល់ការធ្វើឲ្យប្រសើរឡើងនូវការថែទាំសុខភាពមាតា និងទារកនៅកម្ពុជាតាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល និងការអភិវឌ្ឍធនធានមនុស្ស រាប់ចាប់តាំងពីការជួយសាងសង់មជ្ឈមណ្ឌលជាតិគាំពារសុខភាពមាតានិងទារកដោយជំនួយឥតសំណងរបស់ជប៉ុនជាដើម។

ដោយមានកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាការគាំទ្រពីសហគមន៍អ្នកផ្ដល់ជំនួយដែលក្នុងនោះក៏មានរដ្ឋាភិបាលជប៉ុនផងដែរនោះ អត្រាមរណៈមាតានិងទារកបាននិងកំពុងមានសភាពប្រសើរឡើងក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ ទោះជាយ៉ាងណាក៏ដោយ បើប្រៀបធៀបទៅនឹងប្រទេសជិតខាង កម្ពុជានៅតែមានកម្រិតខ្ពស់នៅឡើយ ហើយយើងចាំបាច់ត្រូវធ្វើការកែលម្អស្ថានភាពសុខភាពមាតានិងទារក ជាពិសេសនៅតំបន់ជនបទ។ ក្នុងបរិបទនេះ អង្គការក្រៅរដ្ឋាភិបាលជាច្រើនកំពុងធ្វើកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលកម្ពុជា និងសហគមន៍អ្នកផ្ដល់ជំនួយ ខិតខំប្រឹងប្រែងជួយបង្គ្រប់គ្នាទៅវិញទៅមកដើម្បីកែលម្អធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពមាតា និងទារកនៅកម្ពុជា។

តាមរយៈជំនួយឧបត្ថម្ភសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន ដែលយើងបានផ្តល់ជូនសម្រាប់ ២ ឆ្នាំបន្តបន្ទាប់មកនេះ អង្គការPHJបាននិងកំពុងបន្តអនុវត្តសកម្មភាពដែលមានគោលដៅលើកកម្ពស់ស្ថានភាពសុខភាពមាតា និង ទារកនៅក្នុងស្រុកប្រតិបត្តិ បារាយ៍ - សន្ទុកដែលជាស្រុកជនបទមួយនៅប៉ែកខាងត្បូងខេត្តកំពង់ធំ។ អង្គការPHJបានធ្វើសកម្មភាពជាដំណាក់ៗប្រកបដោយស្ថេរភាព ដូចជាការផ្តល់វគ្គបណ្តុះបណ្តាលអំពីការថែទាំសុខភាពមាតា និងទារកដល់អ្នកស្ម័គ្រចិត្តសុខាភិបាលតាមភូមិចំនួន១១១នាក់ និងបណ្តុះបណ្តាលអំពីគោលការណ៍អនាម័យមូលដ្ឋានដល់មណ្ឌលសុខភាពនិងប្រជាជនក្នុងតំបន់គោលដៅ ព្រមទាំងការគាំទ្រដល់ការបង្កើតបណ្តាញទំនាក់ទំនងនិងផ្តល់ពត៌មានរវាងភូមិ និងមណ្ឌលសុខភាព។ ជាលទ្ធផលយើងបានទទួលដំណឹងថាចំនួនប្រជាជនដែលទទួលបានសេវាថែទាំសុខភាពមាតានិងទារកដូចជាការសម្រាលបុត្រនៅមណ្ឌលសុខភាពដែលមានជំនួយពីឆ្មបជំនាញ និងការមកពិនិត្យផ្ទៃពោះមុនពេលសម្រាលមានការកើនឡើង ហើយការផ្លាស់ប្តូរផ្នត់គំនិត និងសកម្មភាពរបស់ប្រជាជនចំពោះសុខភាពមាតា និង ទារកក៏បានក្លាយជាទង្វើជាក់ស្តែង។

គម្រោងថ្មីសម្រាប់ឆ្នាំនេះគឺជាគម្រោងឆ្នាំចុងក្រោយដើម្បីពង្រឹងបន្តពីគម្រោងឆ្នាំមុនៗដែលនឹងអាចឲ្យប្រជាជនក្នុងតំបន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបន្តអនុវត្តគោលការណ៍នៃគម្រោងប្រកបដោយនិរន្តន៍ភាព។ តាមរយៈគម្រោងឆ្នាំចុងក្រោយនេះ យើងសង្ឃឹមថាប្រជាពលរដ្ឋក្នុងតំបន់ប្រមាណ ៤៧.០០០នាក់ នឹងទទួលបានចំណេះដឹងផ្នែកសុខភាពមាតា និងទារក និងផ្នែកអនាម័យកាន់តែប្រសើរឡើង ព្រមទាំងបន្តអនុវត្តការរស់នៅប្រកបដោយសុខភាព និងអនាម័យដោយខ្លួនឯង។

ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុននេះ គឺដើម្បីផ្តល់ការគាំទ្រដល់គម្រោងអភិវឌ្ឍន៍សង្គម និង សេដ្ឋកិច្ចដែលផ្តល់ប្រយោជន៍ដោយផ្ទាល់ដល់ប្រជាជននៅថ្នាក់មូលដ្ឋាន។ ដោយឆ្នាំនេះជាឆ្នាំខួបលើកទី៦០នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា ខ្ញុំសង្ឃឹមថាគម្រោងដែលចុះហត្ថលេខានៅថ្ងៃនេះនឹងមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ផ្ទាល់ដល់ប្រជាជននៅក្នុងតំបន់គោលដៅប៉ុណ្ណោះទេ គម្រោងនេះក៏នឹងរួមចំណែកជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងជប៉ុន និង កម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!